# សេចក្តីថ្លែងការណ៍ នៃគោលការណ៍
# ស្តីពី អាជីវកម្ម និងសិទ្ធិមនុស្ស នៅព្រះរាជាណាចក្រកម្ពុជា ២០១០

យើងខ្ញុំ ជាសហគ្រាសអាជីវកម្មដែលបានចុះហត្ថលេខាខាងក្រោម តាមរយៈនេះ សូមគោរពតាមគោលការណ៍ដូចតទៅ :

គោលការណ៍ ១: យើងខ្ញុំទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា សិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស ។ ដូច្នេះ យើងខ្ញុំសូមប្រកាសពីគោលបំណងក្នុងការគោរព និង ការពារសិទ្ធិមនុស្ស ដែលទទួលស្គាល់ជាសាកល ។

គោលការណ៍ ២: យើងខ្ញុំប្តេជ្ញាក្នុងការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងទាំងអស់ ពីសកម្មភាពរបស់យើងខ្ញុំ ដោយចាត់វិធានការ ពិសេសក្នុងការធានាឱ្យបាននូវសមភាពសំរាប់អ្នកទន់ខ្សោយ និង អ្នកងាយរងគ្រោះ ។

គោលការណ៍ ៣: យើងខ្ញុំសូមធានាថា កុមារទាំងអស់ត្រូវបានការពារពីការរំលោភសិទ្ធិមនុស្ស ជាក់ស្តែង ដោយគោរពតាមច្បាប់ការងារកម្ពុជា និង បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ទាក់ទងនឹងអាយុអប្បបរមាក្នុងការធ្វើការងារជាដើម ។

គោលការណ៍ ៤: យើងខ្ញុំគោរពចំពោះសេរីភាពនៃការបង្កើតសមាគមន៍ ឬសហជីព ដោយលើកទឹកចិត្តឱ្យកម្មករ និយោជិតមានសិទ្ធិចូលរួមជាមួយសហជីព និង ប្រើប្រាស់សិទ្ធិរបស់គេក្នុងការតវ៉ាជាសមូហភាព ។ លើសពីនេះ យើងខ្ញុំនិងធានាឱ្យបាននូវតម្លាភាព និង ភាពទទួលខុសត្រូវ ដោយរក្សាការពារសេរីភាពបញ្ចេញមតិ និង សេរីភាពទទួលបានព័ត៌មានទាក់ទងនឹងប្រតិបត្តិការរបស់យើងខ្ញុំ ។

គោលការណ៍ ៥: យើងខ្ញុំទទួលស្គាល់សមត្ថភាពជាក់លាក់របស់យើង ដើម្បីលើកតម្កើងសិទ្ធិកម្មករនិយោជិតចំពោះជីវភាពរស់នៅបានគ្រប់គ្រាន់ ហេតុដូចច្នេះ យើងខ្ញុំស្វះស្វែងរកការធានាថា កម្មករនិយោជិតទាំងនោះត្រូវបានផ្តល់ឱ្យនូវ លាភការសមរម្យ និងត្រឹមត្រូវ និង ដោយធានាថា លក្ខខណ្ឌការងាររបស់ពួកគេប្រកបដោយសុវត្ថិភាព និង សុខុមាលភាព ។

គោលការណ៍ ៦: យើងខ្ញុំយល់ដឹងអំពីសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ដូចមានចែងក្នុងច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងធានាឱ្យបាននូវការប្រព្រឹត្តតាមបទដ្ឋានទាំងនេះ ជាពិសេសយើងខ្ញុំជៀសវាងការពាក់ព័ន្ធនឹងការបណ្តេញចេញដោយខុសច្បាប់ ។

គោលការណ៍ ៧: យើងខ្ញុំគោរពសិទ្ធិជនជាតិដើម ទទួលស្គាល់សិទ្ធិកាន់កាប់ជាសហគមន៍លើដីបុព្វបុរស និង ការថែរក្សាវប្បធម៌ ប្រពៃណី និងទំនៀមទំលាប់របស់ពួកគេ ។

គោលការណ៍ ៨: យើងខ្ញុំយល់ថា សមិទ្ធិនៃការការពារសិទ្ធិមនុស្សសំរាប់បុគ្គលគ្រប់រូប អាចប៉ះពាល់ដោយប្រតិបត្តិការ អាជីវកម្មរបស់យើងខ្ញុំ រួមទាំងម្ចាស់សហគមន៍ ដែលតម្រូវឱ្យយើងខ្ញុំគោរពតាមកាតព្វកិច្ចទាំងអស់ ក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា និងជាបន្ថែមទៀត យើងខ្ញុំនឹងគោរពនូវសិទ្ធិទាំងនេះ ទោះបីជាច្បាប់របស់ ព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ ឬមិនអនុវត្តក៏ដោយ ។

គោលការណ៍ ៩: យើងខ្ញុំទទួលស្គាល់ថា អាជីវកម្មអាចមានលទ្ធភាពរំលោភ និង មានការពាក់ព័ន្ធក្នុងបទរំលោភសិទ្ធិមនុស្សតាមរយៈឥទ្ធិពលរបស់ខ្លួន ។ ដូច្នេះ យើងខ្ញុំខិតខំព្យាយាមរៀបចំប្រព័ន្ធផ្ទៃក្នុងឱ្យកាន់តែប្រសើរឡើង ដើម្បីកាត់បន្ថយនូវហានិភ័យដែលអាចកើតមានឡើងជាយថាហេតុ ។

គោលការណ៍ ១០: យើងខ្ញុំទទួលស្គាល់ថា ទោះបីយើងខ្ញុំខិតខំព្យាយាមគោរពសិទ្ធិមនុស្សយ៉ាងណាក្តី ក៏ជម្លោះនៅតែអាចកើតមានឡើងដែរ ។ ដូច្នេះ យើងខ្ញុំចាត់វិធានការអនុវត្តនូវការដោះស្រាយទំនាស់ផ្ទៃក្នុង ដែលអាចផ្តល់ជាសំណងប៉ះប៉ូវឱ្យបានសមរម្យដល់ជនរងគ្រោះ ប្រសិនបើរកឃើញថាមានការរំលោភសិទ្ធិមនុស្ស ។

នាមក្រុមហ៊ុន......CYPL......

នាមអ្នកតំណាងក្រុមហ៊ុន......katha......ហត្ថលេខា......[signature]......ថ្ងៃទី......11/6/10......